BMI0098

សម្ភាសន៍ជាមួយឈ្មោះ ស្មឹត សើយ ភេទស្រី អាយុ៥១ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ សេនាជនភូមិ

សម្ភាសន៍ជាមួយឈ្មោះ សូ យ៉ុន ភេទប្រុស អាយុ៥៣ឆ្នាំត្រូវជាប្ដីរបស់ស្មឹត សើយ

មុខងារនៅសម័យខ្មែរក្រហមៈ ជាងឡាននៅយានដ្ឋានយ-១

សព្វថ្ងៃរស់នៅភូមិយាងវ៉ាន ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ហ៊ិន សុធានី

០០:៤៣:៥៩

៣១ទំព័រ

ធានី : ថ្ងៃហ្នឹងថ្ងៃទី៨ ខែ១២ ឆ្នាំ២០១០ ។ ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា មីងដែលជាកន្លែងអង្គការក្រៅរដ្ឋាភិបាល ។ ហើយការងាររបស់ពួកខ្ញុំ គឺមកនេះសុំអនុញ្ញាតិមីងសម្ភាសន៍ដើម្បីយកសាច់រឿងទាំងអស់ហ្នឹងយកទៅធ្វើជាសៀវភៅ សម្រាប់ឲ្យក្មេងៗក្រោយៗបានអានបានមើលដឹងចឹង?

សើយ : ចា៎!

ធានី : ហើយរឿងរ៉ាវអស់ហ្នឹង ខ្ញុំសុំអនុញ្ញាតិរបៀបថាធ្វើទុកឲ្យក្មេងៗក្រោយ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវផ្សេងៗ បានសិក្សាស្រាវជ្រាវអីចឹងបានមីង?

សើយ : ចា៎!

ធានី : ចា៎! ចឹងមីងខ្ញុំសុំថតជាសម្លេង ក៏ដូចជាថតជារូបបានទេមីង?

សើយ : ថតរូបទៀត ។

ធានី : ចា៎! សុំថតរូប ។

សើយ : បើអត់ ចេះថត ។

ធានី : បានអត់មីង?

សើយ : ថតរូបទៀត ចាស់ឡើងរូប ធំតែធ្មេញ ។

ធានី : អត់អីទេមីង បើចឹងជូនកាលចៅអត់ដឹងៗថាយាយ អូ!កាលយាយនៅក្មេងអីចឹងមីង ។ ម៉េចដែលអត់អីទេមីង?

សើយ : មានអី ។

ធានី ៖ មីងឈ្មោះអីគេ?

សើយ ៖ ខ្ញុំឈ្មោះ សើយ ។

ធានី ៖ អីគេសើយ?

សើយ ៖ ស្អិត សើយ ។

ធានី ៖ ស្អិត?

សើយ ៖ ចាំ!

ធានី ៖ ស្អិត?

សើយ ៖ សើយ ។

ធានី ៖ ស្អិត សើយ?

សើយ ៖ ចាំ!

ធានី ៖ មីងឆ្នាំហ្នឹងអាយុប៉ុន្មានហើយ?

សើយ ៖ ៥១ ។

ធានី ៖ ៥១ឆ្នាំ ។ មីងមានស្រុកកំណើតនៅណាវិញ?

សើយ ៖ ស្រុកកំណើតនៅភូមិយាងវេននេះ ។

ធានី ៖ ស្រុកកំណើតភូមិយាងវេន ។ ឃុំអីគេ?

សើយ ៖ ឃុំផ្គាំ ស្រុកស្វាយចេក ។

ធានី ៖ ស្វាយចេក ខេត្តបន្ទាយមានជ័យ?

សើយ ៖ ចាំ!

ធានី ៖ ចឹងស្រុកកំណើតរបស់មីងនៅហ្នឹង សព្វថ្ងៃក៏មីងរស់នៅហ្នឹងដែរ?

សើយ ៖ ចាំ! នៅហ្នឹង ។

ធានី ៖ ឪពុកមីងឈ្មោះអីគេ?

សើយ ៖ ស្អិតហ្នឹងហើយ ។

ធានី ៖ ស្អិត អីគេស្អិតទៅ? អូ! ឪពុកមីងបរទេសមែន?

សើយ ៖ ទេ! គាត់ស្លាប់បាត់ ។

ធានី ៖ គាត់ជាខ្មែរយើងតើ?

សើយ ៖ ខ្មែរ ។

ធានី ៖ ឈ្មោះដូរបរទេសចឹង ស្អិតៗ?

សើយ ៖ ស្ទិត ។

ធានី ៖ ស្ទិត អឺ! ស្លាប់ពេលបដិវត្ត?

សើយ ៖ ចាំ!

ធានី ៖ ស្លាប់ឆ្នាំប៉ុន្មាន មីងចាំទេ?

សើយ ៖ ឆ្នាំប៉ុន្មានទេ ឆ្នាំ៩០ ឪពុកស្លាប់ខ្ញុំដឹងក្តី៨៥ ពុកខ្ញុំស្លាប់៨៩នេះឯង ។

ធានី ៖ អឺ! ១៩៨៩ ម្តាយមីងឈ្មោះអីគេ?

សើយ ៖ ឈ្មោះ ហាន ។

ធានី ៖ គាត់ស្លាប់ពេលណាដែរ ហើយក៏នៅរស់?

សើយ ៖ គាត់ស្លាប់ហើយ ។

ធានី ៖ ស្លាប់ពេលណាដែរមីង?

សើយ ៖ ស្លាប់ពីឆ្នាំប៉ុន្មានទេ ៨៨ ៨៩នេះឯង ។

ធានី ៖ ដូចគ្នាដែរ?

សើយ ៖ ចាំ!

ធានី ៖ ៨៩មីងណា?

សើយ ៖ ចាំ!

ធានី ៖ មីងមានបងប្អូនប៉ុន្មាននាក់?

សើយ ៖ បងប្អូនខ្ញុំ៨នាក់ ស្លាប់អស់៣ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សើយ ៖ ស្រីតែខ្ញុំមួយពៅគេ ។

ធានី ៖ ស្រី ចឹងប្រុស៧ ស្រីម្នាក់?

សើយ ៖ ចាំ!

ធានី ៖ មីងពៅគេទៀត?

សើយ ៖ ពៅគេ ។

ធានី ៖ ដល់ពេលស្លាប់ៗបងប្រុស?

សើយ ៖ ស្លាប់បងប្រុស ។

ធានី ៖ ប្រុសប៉ុន្មាន៣នាក់?

សើយ ៖ ស្លាប់ប្រុស៣នាក់ ទាំង៣ សព្វថ្ងៃនៅសល់៥នាក់ ។

ធានី ៖ ចា៎! នៅសល់៥ត្រូវហើយ ។ ៨ស្លាប់អស់៣ នៅសល់៥ ។ មីងបានរៀនបានអីដែរ?

សើយ ៖ អត់បានរៀនផង សម័យបដិវត្តក៏ ។

ធានី ៖ ចូលបដិវត្ត?

សើយ ៖ រៀនតិចតួចក៏មិនចេះបានតែម៉ាអានឈ្មោះខ្លួនឯងតិច ។

ធានី ៖ អូ! ចឹងពេលទៅបដិវត្តមីងបានចូលរៀនដែរ?

សើយ ៖ អត់ទេ គេឲ្យចូលនារីសេនាជន ។

ធានី ៖ ចូលបដិវត្តឆ្នាំប៉ុន្មាន?

សើយ ៖ ឆ្នាំ៧៥ ។

ធានី ៖ ៧៥ហ្នឹងធ្វើនារីសេនាជន?

សើយ ៖ ចា៎!

ធានី ៖ ធ្វើអីខ្លះទៅនារីសេនាជនហ្នឹងមីង?

សើយ ៖ គេឲ្យលីកាំភ្លើង ដើរធ្វើការតាមប្រជាជនតាមភូមិ ។

ធានី ៖ ធ្វើការតាមប្រជាជនតាមភូមិម៉េចទៅ?

សើយ ៖ ដូចថាប្រជាជនធ្វើស្ទូងដកក៏ទៅជួយគេ ។

ធានី ៖ អូ! ជួយដកស្ទូងប្រជាជនដែរ?

សើយ ៖ ចា៎!

ធានី ៖ ចឹងលីកាំភ្លើងធ្វើអី?

សើយ ៖ គេឲ្យលី មិនដឹងថាអីសម័យគេនោះ ។

ធានី ៖ កាលហ្នឹងមីងនៅក្មេងដែរ លីទៅមិនធ្ងន់ណាស់?

សើយ ៖ កាំភ្លើងតូចៗ ។

ធានី ៖ ហើយមីងធ្វើសេនាជន ឬក៏មុខងារជាអីដែរ?

សើយ ៖ មានមុខងារអីទេ ។

ធានី ៖ សមាជិកគេ ឬក៏?

សើយ ៖ ធ្វើកូនគេ ។

ធានី ៖ កូនគេ?

សើយ ៖ ចា៎!

ធានី ៖ សេនាជនតែមីងម្នាក់ឯងទេ?

សើយ ៖ វាច្រើនគ្នាណាស់ឯង ប៉ុន្តែម៉ាឃុំវាមាន២-៣នាក់ ។

ធានី ៖ ចឹងតែមីងស្រីម្នាក់ឯង ឬក៏មានគេស្រីដែរ?

សើយ ៖ ស្រីកំប៉េសរាប់រយ ។

ធានី ៖ អូ! ចឹងភូមិមីងហ្នឹងគឺមាន៣នាក់?

សើយ ៖ ភូមិខ្ញុំនោះ ។

ធានី ៖ ចាំ!

សើយ ៖ មានច្រើនដែរ ប៉ុន្តែគេរត់មកផ្ទះអស់ទៅ ក៏នៅតែខ្ញុំ ។

ធានី ៖ ចឹងកាលពេលមីងធ្វើសេនាជននៅណាវិញ?

សើយ ៖ នៅ មុនដំបូងនៅថ្មពួក ។

ធានី ៖ ទៅណាទៀតទៅមីង?

សើយ ៖ នៅថ្មពួកទៅគេបញ្ជូនទៅនៅគោករមៀត ស្រែល្អ តាសុំ គោកព្រេច ។

ធានី ៖ ស្រែកល្អ តាសុំ គោកព្រេច?

សើយ ៖ ចាំ!

ធានី ៖ ហើយដល់ពេលទៅនៅកន្លែងណាបានគេនាំគ្នារត់អស់?

សើយ ៖ ទេ ដល់ពេលទៅនៅឯនោះគេដក ខ្ញុំចូលកន្លែងដេរ ។

ធានី ៖ នៅណាវិញ?

សើយ ៖ ដេរនៅស៊ីសាផុនឯស្វាយយើង ។

ធានី ៖ ទៅនៅស្វាយហ៎?

សើយ ៖ ចាំ!

ធានី ៖ ស្វាយស៊ីសាផុនធ្វើជាអ្នកដេរៗអីគេមីង?

សើយ ៖ ដេរខោអាវ កងទ័ពជាតិនោះឯង ខោអាវបើកយកមកបើកឲ្យប្រជាជនយើងហ្នឹង ។

ធានី ៖ ខោអាវខ្មៅហ្នឹងមីង?

សើយ ៖ ខោអាវខ្មៅ ខោអាវសហ្នឹង ។

ធានី ៖ ខោអាវខ្មៅឲ្យប្រជាជនយើង?

សើយ ៖ ចាំ!

ធានី ៖ នៅណាវិញកន្លែងដេរ ស្វាយស៊ីសាផុនកន្លែងណា?

សើយ ៖ ដេរនៅស្វាយហ្នឹងឯង ។

ធានី ៖ ដេរនៅកន្លែងស្វាយហ្នឹង?

សើយ ៖ ចា៎!

ធានី ៖ មីងមិញថាមីងនៅកាត់ដេរ នៅស្វាយស៊ីសាផុនហ្នឹង កាត់ដេរហ្នឹងកាត់ដេរតែម៉ាមុខទេ អត់មានធ្វើអីទៀតទេ?

សើយ ៖ អត់ទេ ។

ធានី ៖ អត់ទេមីង តែប៉ុនហ្នឹង?

សើយ ៖ ដេរ បើកាត់ដេរចេះ បើថ្ងៃម៉ោង១១បានហូបបបរ ។ ចាប់ពីម៉ោង១១ដេរហើយចុះធ្វើការ

ដាំស្ពៃ ដាំពោត ដាំសណ្តែក តាមមុខផ្ទះ ។

ធានី ៖ បន្ទាប់មកម៉ោង៣ដាំសណ្តែកទៀត?

សើយ ៖ ចា៎! ដាំដី សព្វគ្រប់ប៉ុននោះឯង ស្ពៃ ។

ធានី ៖ ដាំបន្លែចឹងមីង?

សើយ ៖ អឺ!

ធានី ៖ ដាំធ្វើអីគេមីង?

សើយ ៖ ដាំហូបខ្លួនឯង ។

ធានី ៖ អាហ្នឹងអ្នកណានៅអ្នកណា អ្នកហ្នឹងដាំខ្លួនឯង?

សើយ ៖ ចា៎! ដូចថាបន្ទប់យើង ដែលយើងនៅដេរចឹង គេដាំតាមមុខបន្ទប់ចឹង ។

ធានី ៖ ហើយសម្រាប់ហូបខ្លួនឯង?

សើយ ៖ ដាំហូប ។

ធានី ៖ មិនមែនហូបរួមទេ?

សើយ ៖ ហូបរួមជុំគ្នាហ្នឹងឯងរួមម៉ាក្នុងម៉ាកន្លែងដេរចឹងគ្នា៣៥០នាក់ ។

ធានី ៖ ៣៥០នាក់?

សើយ ៖ ចា៎!

ធានី ៖ អ្នកណាប្រធាននៅហ្នឹង?

សើយ ៖ អឺ! ប្រធានគេឈ្មោះអី ខ្ញុំមិនដែលស្គាល់ទេ ។

ធានី ៖ បន្ទាប់មកទៀត ធ្វើអីទៀតមីង?

សើយ ៖ បន្ទាប់មកទៀត ក៏ខ្ញុំស្ទើកជើង ខ្ញុំសុំគេមកផ្ទះ ។

ធានី ៖ ពេលណាទៅ នៅដេរបានប៉ុន្មានខែ បានប៉ុន្មានថ្ងៃ?

សើយ ៖ ដេរបានរយៈប្រហែលជា៣ខែ។

ធានី ៖ អូ! រយៈពេល៣ខែ?

សើយ ៖ ចា៎!

ធានី ៖ ៣ខែ ស្ដីកដើងសុំមកផ្ទះ?

សើយ ៖ សុំមកផ្ទះ។

ធានី ៖ ម៉េចទៀតមីង?

សើយ ៖ ដល់ពេលមកដល់ផ្ទះ ពុកខ្ញុំគាត់រត់ទៅថៃ។

ធានី ៖ ម៉េចទៅមីង?

សើយ ៖ គាត់រត់ទៅថៃចឹងទៅ ខ្ញុំក៏អត់បានទៅវិញហ្នឹងគេព្រោះមេគេនេះគេចោទថាឪពុកខ្ញុំគេ កូនគេថាខ្ញុំនេះកូនក្បត់។

ធានី ៖ ចោទមីង?

សើយ ៖ ចា៎! ថាឪពុកខ្ញុំ ដល់គេថាខ្ញុំកូនខ្ញុំថា អឺ!កូនអា្ហឪរត់ទៅថៃ ពួកគេណាគេថារត់ទៅថៃ មិនបាច់ហៅវាមកវិញទេ។

ធានី ៖ អូ! គេនិយាយចឹងទៀត?

សើយ ៖ ចា៎!

ធានី ៖ ហើយម៉េចទៀតមីង?

សើយ ៖ ខ្ញុំនៅផ្ទះទៅ។

ធានី ៖ ចឹងមីងនៅផ្ទះពីហ្នឹងរហូតមកដល់?

សើយ ៖ ចាស៎! រហូតដល់សព្វថ្ងៃ។

ធានី ៖ តែគេមានធ្វើបាបអីមីងដែរអត់ បើមីងអត់ទៅកន្លែងធ្វើការមីងចឹង គេមានហៅ?

សើយ ៖ ទេ! គេគ្រាន់ថាគំរាមកំហែងអីដែរ គេថាបើមិនមកទេ គេយកមិត្តយើងចាប់ឲ្យក៏ខ្ញុំមិនរក។

ធានី ៖ អ្នកណាអ្នកមកកគំរាម អ្នកណាអ្នកគំរាមមីង?

សើយ ៖ មេគេនោះឯងនៅស្វាយហ្នឹងឯង។

ធានី ៖ ស្គាល់ឈ្មោះគេទេមីង?

សើយ ៖ មិនដឹងឈ្មោះអីគេទេ។

ធានី ៖ ចឹងពេលពុកមីងរត់ទៅថៃ មានត្រឡប់មកវិញទេ?

សើយ ៖ អត់ទេ ពុកខ្ញុំស្លាប់នៅនោះឯង ។

ធានី ៖ អូ! ស្លាប់នៅថៃ?

សើយ ៖ ចាំ! ស្លាប់នោះឯង មិនបានឃើញឆ្អឹងឃើញអីទេ គាត់ស្លាប់ ។

ធានី ៖ ចឹងម៉េចបានមីងដឹងថាពុកមីងស្លាប់នៅហ្នឹង?

សើយ ៖ ចុះបើអ្នកទៅទាំងអស់គ្នា មានអ្នកណាមកវិញផង ៦នាក់ស្លាប់ទាំងអស់ ។

ធានី ៖ អូ! រត់ទៅថៃមីងនោះ?

សើយ ៖ រត់ទៅថៃ ។

ធានី ៖ ហើយបន្ទាប់មកទៀត មីងចាំទេ ថាឆ្នាំប៉ុន្មាន ដែលមីងត្រឡប់មកលេងផ្ទះ បើ៧៩មីងនៅសេនាជន បន្ទាប់មកទៅកាត់ដេរវិញ?

សើយ ៖ នៅ ហ្នឹង៧៩ខ្ញុំនៅថ្មពួក ដល់ពេលខ្ញុំត្រឡប់មកវិញវា៧៧ ។

ធានី ៖ ១៩៧៧មកលេងផ្ទះមីង?

សើយ ៖ ចាំ!

ធានី ៖ មកលេងផ្ទះដោយសារមីងឈឺស្ពឹកជើងទេ?

សើយ ៖ ស្ពឹកជើង ដេរមិនបាន មកផ្ទះ ។

ធានី ៖ មីងដឹងថាហេតុអីបានមីងស្ពឹកជើង មានពេទ្យគេមើលគេអី?

សើយ ៖ អត់ទេ បើនែក! ដេរៗយូរទៅនៅផ្ទះថ្មនៅអាផ្ទះចេះ ដេរទាំងយប់ទាំងថ្ងៃ យប់ម៉ោង១២ បានឲ្យសម្រាក ។ ដល់ដេរៗយូរទៅរៀងស្ពឹកជើង ហើយទៅដេក គេឲ្យទៅដេកពេទ្យមន្ទីរលើ អាស្មាយឃើងនឹងភ្នំនោះ ឲ្យដេកនោះឯង អត់មានថ្នាំអីចាក់ទេ មានតែម្ទូរការវិជ្ជាសាស្ត្រគេ ប្រវែង១នេះគេខែ១ដូចថាស្ពឹកចឹងគេខែ១ឡើងលិចត្បូលចេះ ក្រោកឡើងក៏ខ្ញុំស្ទុតដួល១នឹង ស៊ីម៉ង់នឹង ហើយក៏មកមិនបាន ណាំនឹកម៉ែ នឹកពុកផង ផងទៅសុំចេញមក ។

ធានី ៖ សុំគេឲ្យបានមកផ្ទះ មីង?

សើយ ៖ ហ្នឹងហើយគេបើក ដូចថាម៉ាឃុំផ្កាំនេះគេបើកឲ្យមកប៉ុន្មាននាក់ ៥នាក់ ដូចថាស្រុកត្រពាំងថ្មចេះឲ្យមកលេងផ្ទះ ម្តង៥នាក់ ។ អ្នក៥នាក់ទៅវិញ បានមានអ្នក៥នាក់មកទៀត ។

ធានី ៖ អូ! ដល់ពេលមីងអត់ទៅ?

សើយ ៖ ចាំ! ខ្ញុំអត់ទៅ ។

ធានី ៖ ហើយចុះមីងកាលពេលមីងមកលេង ប្រហែលបានប៉ុន្មានខែ ប៉ុន្មានថ្ងៃ បានគេៗដាក់សំបុត្រមក ឬក៏គេដាក់?

សើយ ៖ បានប្រហែលជា មិនដល់ម៉ាអាទិត្យផង គេមកហៅ ។

ធានី ៖ អ្នកណាគេមកហៅ មីងចាំ?

សើយ ៖ ចាំ! គេផ្តាំតាមមិត្តយើងមកថាឲ្យទៅវិញ ខ្ញុំមិនបានទៅខ្ញុំថាអត់បានទៅទេ ឪពុកខ្ញុំ គ្មានអ្នកណានៅមើលម្តាយខ្ញុំ សុទ្ធតែគេអ្នកមានកូន ។

ធានី ៖ បងៗមីងទៅណាអស់ទៅ?

សើយ ៖ បងៗគេបែករំពេលអស់ទៅ ក៏នៅតែ២នាក់ម៉ែកូន បងមួយគាត់ស្លាប់នៅជំរំថ្មី ។

ធានី ៖ ចឹងមីង ចុះយួនចូលស្រុក មីងរត់ទៅណាវិញ?

សើយ ៖ យួនចូលស្រុកនឹង រត់ទៅនៅនោះអំពិលក្តុល ។

ធានី ៖ នៅអំពិលក្តុល?

សើយ ៖ ចាំ! នៅស្រុកអំពិលក្តុល ស៊ីលេនោះ ។

ធានី ៖ ស្រុកអំពិលហ្នឹងនៅណាវិញ?

សើយ ៖ នៅជើងភ្នំដងរែក ។

ធានី ៖ អឺ! ជើងភ្នំដងរែកហ្នឹងគេហៅស្រុកអំពិល?

សើយ ៖ ចាំ! ស្រុកអំពិល ស្រុកស៊ីលេន ។

ធានី ៖ គូលេន ស៊ីលេន?

សើយ ៖ ស៊ីលេន ។

ធានី ៖ ស៊ីលេន?

សើយ ៖ ស្រុកស៊ីលេន ។

ធានី ៖ ចឹងបានមីងទៅនៅហ្នឹងទៅ បានទៅជួបពូទៅមីង?

សើយ ៖ ទេ! មកជួបគ្នានៅផ្ទះនេះ ។

យ៉ុន ៖ អ៊ុនគាត់ចូលប្រហែលជាម៉ាខែខ្ញុំរៃបែកសមរភូមិអស់ បានគេដកគ្នាចេញទៅក៏ខ្ញុំឈប់អស់បុណ្យអស់សក្តិ ក៏ខ្ញុំឈប់ គេដកកូនស្ពៃ ចឹងបានថាការតស៊ូទាំងប៉ុន្មាន គឺគុណសម្បត្តិវាមានច្រើនណាស់ ប៉ុន្តែរឿងខុសតិចតួច ។

ធានី ៖ ទៅជារឿងធំវិញ?

យ៉ុន ៖ បាទ! ទំនាស់គ្នាតិចតួច....ឈប់ទៅ.......... ។

ធានី ៖ ចឹងអញ្ជើញមកនេះតិចមកចង់សួរពូតិច ។

សើយ ៖ ខ្ញុំប៉ុនហ្នឹងបានហើយ ។

ធានី ៖ ចា៎ៗ ពូអញ្ជើញតិចមកពូនោះ ចង់សួរពូតិច ស្ដាប់រឿងពូមើលទៅវាកំសត់ខ្លាំងណាស់ខំប្រឹងតស៊ូ ។

យ៉ុន ៖ គ្មានស្អី ឆ្អែតអស់ សព្វថ្ងៃគ្រាន់តែឃើញឯកសណ្ឋានយោធា មិនមែនថាស្អប់ខ្ពើមនឹងស្នេហាជាតិទេ.......កាលដែលសមាហរណកម្មគេចាប់ខ្ញុំបាញ់ចោល ប៉ុន្ដែខ្ញុំរត់រួចទៅក៏ ខ្ញុំបានស្បថស្បែរថាគេយកមកយកព័ត៌មានពីខ្ញុំច្រើនដែរ ។ ខ្ញុំថាពិនិត្យមើលទៅបើក្រុមគ្រួសារខ្ញុំ បើថាមានឯកសណ្ឋានអីហ្នឹងខ្ញុំប្រគល់ជីវិតឲ្យ ។

ធានី ៖ មានគេមកមើលផ្ទះពូ?

យ៉ុន ៖ គេមនចាប់ខ្ញុំ ។

ធានី ៖ ហេតុអីពូ?

យ៉ុន ៖ រឿងកាលនោះមិនប៉ារ៉ាមិនចូលទៅខាងរដ្ឋាភិបាលកម្ពុជា ។ ហើយខ្ញុំឈប់មុនអាណត្តិនឹង ខ្ញុំរំលាយដោយខ្លួនឯងតែម្ដង អត់មានអ្នកណាមករំលាយឲ្យខ្ញុំទេ ខាងណាក៏ខ្ញុំមិនចូល ខ្ញុំនៅជាប្រជាជនសាមញ្ញធម្មតា ប៉ុនថាកាលនោះវានៅក្នុងលក្ខណៈមួយប្រទាញប្រទុងណា ។ ដល់ចឹងទៅ ខ្ញុំចេះធ្វើឡានធ្វើអីទៅក៏អ្នកដឹកនាំដូចគ្នា ក៏គេធ្លាប់ដឹងក៏គេហៅខ្ញុំទៅថ្មពួក ទៅធ្វើអាត្រាក់ធ្វើអីឲ្យគេ ។ បានថារឿងនេះ ។

ធានី ៖ ម៉េចទៀតពូ?

យ៉ុន ៖ បាទ! ដល់នេះ ខ្ញុំមិនទៅទទួលនិន្នាការនយោបាយគេ ធ្វើឡានធ្វើអីណា ពេលណាខ្លះគេឲ្យ ១០០....។ ខ្ញុំទទួលឥទ្ធិពលនយោបាយអី ។

ធានី ៖ គេតាមដានពូម៉េចនិយាយនោះ?

យ៉ុន ៖ តាមដានខ្ញុំថាធ្វើការ ខាងប៉ារ៉ាពីដើមមិញ ។

ធានី ៖ ចា៎!

យ៉ុន ៖ ពីដើមមិញគេថាខាងអាអ៊ិនហ្វ ខាងរិទ្ធីសែនខាងអី ។ ហើយខ្ញុំបានអស់ហើយ ជម្រាបអស់ប្រធានភូមិគាត់កាន់ក្ដាប់ខ្ញុំដឹងអស់ កិច្ចការងារក្នុងភូមិអីក៏ខ្ញុំចេះតែជួយ ឯកសណ្ឋានអីក៏ខ្ញុំលះបង់អស់ និយាយរួមទៅអាជីព គឺប្រជាជនធម្មតា ។ ប៉ុន្ដែដល់គេអ្នក ចលនាអ្នកតស៊ូគេថាកំទេចក្បាលទាហានមេដឹកនាំឲ្យអស់ ។

ធានី ៖ ម៉េចទៀតពូ ចឹងដំបូងពូធ្វើនៅប៉ារ៉ា?

យ៉ុន ៖ ទេ!

ធានី ៖ ប៉ាវ៉ា នៅខ្មែរក្រហម?

យ៉ុន ៖ បាទ!

ធានី ៖ នៅខ្មែរក្រហម ហើយគេថាពូធ្វើប៉ាវ៉ា?

យ៉ុន ៖ បាទ! នោះហើយ ជារួមខ្ញុំធ្វើយូរហើយ ចេញពីឆ្នាំ១៩៧៣ ខែ១ ។

ធានី ៖ ១៩៧៣ ពូចេញពីណាមកវិញ?

យ៉ុន ៖ មកចេញពីខេត្តតាកែវ ស្រុកកំណើតខ្ញុំណា ខ្ញុំចេញកាលពីមុនប៉ាខ្ញុំគាត់អតីតជាជំទុកលេខ១ ពីជំនាន់សង្គមរាស្ត្រនិយម ។ បាទ! ដល់ចឹងទៅ ថាជាប់និន្នាការ ឪពុកម្តាយលះបង់កូនចៅ ។ ខ្លាចចេញទាំងអស់គ្នា ខ្ញុំពៅគេ ដល់ចេញបងខ្ញុំស្លាប់អស់ទៅរបួត ខ្ញុំចេះតែតស៊ូរហូតដល់៧ មករា ៗ ក៏វៃចប់ភ្នំពេញ ក៏ខ្ញុំនៅភ្នំពេញ ។

ធានី ៖ អូ! ពេលហ្នឹង ពូនៅភ្នំពេញដែរ?

យ៉ុន ៖ បាទ! ពេលចប់ទៅខ្ញុំនៅភ្នំពេញក៏រៀនបច្ចេកទេសឡាន រៀនទៅក៏ ។

ធានី ៖ ៧៥ ឬក៏៧០?

យ៉ុន ៖ ៧៥ យើងសន្តិភាព ។

ធានី ៖ អូ! ៧៥ យើងសន្តិភាពពូនោះ?

យ៉ុន ៖ បាទ! នោះហើយ ។

ធានី ៖ ពូនៅភ្នំពេញ?

យ៉ុន ៖ បាទ! ខ្ញុំនៅផ្សារតាខ្មៅ ពីដើមមិញគេហៅផ្សារដើមមៀនជាប់ ។

ធានី ៖ នៅធ្វើអីគេពូ ផ្សារដើមមៀនហ្នឹង?

យ៉ុន ៖ ហ្គារ៉ាសឡាន យាន្តដ្ឋានយ-១ ខ្ញុំនៅជាង ។

ធានី ៖ យាន្តដ្ឋានយ-១ហ្នឹង?

យ៉ុន ៖ បាទ! គេដកពីយោធាមកឲ្យរៀនឡាននោះឯង ដល់ខ្ញុំគិតឃើញថាពីសង្គមក៏វាមិនឆាយដែរ បច្ចេកទេសអីចឹង ចេះខំតស៊ូរៀនៗក៏ពាក់កណ្តាលឆ្នាំ១៩៧៨នោះហើយ ដល់ខ្ញុំនៅរៀនឡាន សាលារៀនទួលគោក កាលហ្នឹងចិនមកពីប៉េកាំងគេបង្រៀន ។ ប៉ុនខ្ញុំស្នាក់នៅៗផ្សារថ្មីកន្លែង ក្រសួងខស្សរាហកម្ម ពីដើមមិញអ៊ំចេង អន ជាក្រសួងខស្សរាហកម្ម ខ្ញុំរៀនចប់ទៅដកខ្ញុំទៅ ផ្សារតាខ្មៅវិញ ហើយក៏ឃ្លួនចូលៗទៅចេះតែរត់បន្តៗកាន់អាវុធ ចេះតែវៃឃ្លួនបណ្តើររត់ បណ្តើតរបួតរហូត នៅទើបខាងត្បូងថ្នល់ ដកមកខាងជើងថ្នល់វិញ ។ ឪពុកម្តាយបងប្អូនស្លាប់

អស់ សព្វថ្ងៃ ចុះដែលខ្ញុំបានជួបប្រពន្ធក៏វៀយួនឆ្នាំប៉ុន្មានមុនអ៊ុនគាក់ចូល ខ្ញុំឈប់រំដោះតាម ភារកិច្ចតាមបុណ្យសក្តិណា៎ ។ បាទ! ខ្ញុំឈប់ ។

ធានី : ចឹងដំបូងមកនៅឆ្នាំ៧៣ ពូចូលបដិវត្តនៅស្រុកភូមិពូហ្នឹង ស្រុកកំណើតនៅណាវិញ?

យ៉ុន : អឺ! ភូមិឫស្សីថ្មី ។

ធានី : ភូមិឫស្សីថ្មី?

យ៉ុន : បាទ! ឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

ធានី : ចឹងពូចេញពីហ្នឹងទៅ ចឹងអ្នកណាគេអ្នកហៅពូចូល អ្នកនាំពូចូល?

យ៉ុន : ដែលនាំចូលនោះ គឺស្លាប់អស់ហើយ គេយកទៅវៃចោលងាប់អស់ហើយ ។

ធានី : ឈ្មោះអីគេ?

យ៉ុន : នែក! ពូខ្ញុំគាត់ប្រធានកងភូមិភាគពិសេស ឈ្មោះពូណាត ។

ធានី : ពូណាត?

យ៉ុន : បាទ! ស្លាប់ ។

ធានី : តាណាតប្រធានកងពលហ្នឹង មែន?

យ៉ុន : បាទ!

ធានី : កងពលលេខប៉ុន្មានពូពី កាលហ្នឹង គាត់?

យ៉ុន : ខ្ញុំ ។

ធានី : ពេល៧៥ហើយ ប្រធានកងពលលេខប៉ុន្មាន?

យ៉ុន : ខ្ញុំចាំតែកងពលប្រធានភូមិភាគពិសេសប៉ុននោះឯង លេខភ្លេចអស់ហើយ ។

ធានី : ពូណាត ប្រធានកងពល ។ ភូមិភាគពិសេសហ្នឹងប្រចាំនិរតីហ្នឹងឬក៏ម៉េច?

យ៉ុន : បាទ!

ធានី : ជាពូបង្កើតរបស់ពូ?

យ៉ុន : បាទ!

ធានី : នាំពូចូលតែម្នាក់ឯងទេ ឬក៏មានអ្នកផ្សេងទៀតចូលដែរ?

យ៉ុន : ចូលច្រើនដែរ ប៉ុនគេស្លាប់អស់ ។

ធានី : បងប្អូនពូដែរ?

យ៉ុន : អ្នកសាច់ញាតិនៅក្នុងភូមិហ្នឹងនោះ ។

ធានី : អូ! ជាញាតិមិត្តនៅក្នុងភូមិ?

យ៉ុន ៖ បាទ!

ធានី ៖ តែបងប្អូនពូអត់ចូលជាមួយពូទេ ពេលចូល ចុះឪពុកពូអី?

យ៉ុន ៖ ពេលចូលបែកគ្នាទាំងអស់ ។

ធានី ៖ ចឹងដំបូងពូណាគេហ្នឹងអ្នកនាំចូលទាំងអស់គ្នា?

យ៉ុន ៖ បាទ! បងខ្ញុំបន្ទាប់ហ្នឹងហើយគាត់រួចបានខ្ញុំ គាត់ស្លាប់នៅនែក!បន្ទាយក្រាំងខ្នារ មុនសន្តិភាព ប្រហែលជាប៉ុន្មាន ៤-៥ខែ ។

ធានី ៖ អូ! ស្លាយដែរពូនោះ?

យ៉ុន ៖ អឺ!

ធានី ៖ ដោយសារអីគេ វៃនៅណា?

យ៉ុន ៖ វៃៗនៅបន្ទាយក្រាំងខ្នារ ។

ធានី ៖ ឈ្មោះអីគេបង?

យ៉ុន ៖ ឈ្មោះ យ៉ុង ។

ធានី ៖ យ៉ុក?

យ៉ុន ៖ បាទ! ឈ្មោះ សូ យ៉ុង ។

ធានី ៖ សូ យ៉ុង?

យ៉ុន ៖ បាទ! ខ្ញុំឈ្មោះយ៉ុន ។

ធានី ៖ សូ យ៉ុងហ្នឹងគាត់វៃគ្នានៅបន្ទាយ?

យ៉ុន ៖ បន្ទាយក្រាំងខ្នារ ។

ធានី ៖ ក៏ស្លាប់ទៅ?

យ៉ុន ៖ បាទ!

ធានី ៖ តែបងពូ ហើយនឹងពូទេ?

យ៉ុន ៖ បាទ!

ធានី ៖ ដែលបានចូលបដិវត្ត ដែលពូដឹកនាំ?

យ៉ុន ៖ ធ្វើទាំងអស់ បងមួយនៅថ្មគោល ប្រធានឃុំ ។

ធានី ៖ ចុះឪពុកពូនោះ?

យ៉ុន ៖ ប៉ាខ្ញុំ គាត់ចាស់ គាត់អត់បានធ្វើទេ ។

ធានី ៖ បងស្រី បងប្រុសនៅថ្មគោល ធ្វើប្រធានឃុំ?

យ៉ុន ៖ ឈ្មោះ យិន ប្រុស ។

ធានី ៖ រាល់ថ្ងៃគាត់នៅទេ ឬក៏?

យ៉ុន ៖ នៅ ។

ធានី ៖ ជាប្រធានឃុំថ្មគោល?

យ៉ុន ៖ អត់ទេ សព្វថ្ងៃមិនៗគាត់ធ្វើទេ ប៉ុនពីមុនគាត់ប្រធានឃុំចំប៉ា ។

ធានី ៖ ជាប្រធានឃុំចំប៉ា ប្រធានឃុំពូរស់នៅហ្នឹង?

យ៉ុន ៖ បាទ!

ធានី ៖ ចឹងបងយិនរបស់ពូហ្នឹងគាត់ ប្រធានឃុំចំប៉ា ហើយបងប្រុសយ៉ុង គាត់?

យ៉ុន ៖ ទ័ព ។

ធានី ៖ គាត់ធ្វើទ័ព?

យ៉ុន ៖ បាទ!

ធានី ៖ គាត់ប្រធានអីដែរអត់ទេ?

យ៉ុន ៖ គាត់ពីដើមមិញគាត់កាន់អនុសេនាធំ ។

ធានី ៖ បន្ទាប់មកទៀត បានពូណាត?

យ៉ុន ៖ បាទ!

ធានី ៖ ចុះពូៗ កាលហ្នឹងពូកាន់អីគេ ពេលពូធ្វើបដិវត្ត?

យ៉ុន ៖ ខ្ញុំមិនទាន់មានកាន់អីទេ ទើបមកសម័យយួនចូលនេះ ខ្ញុំកាន់វរៈសេនាធំ ។

ធានី ៖ អូ! ដល់យួនចូលបានធ្វើ?

យ៉ុន ៖ បាទ!

ធានី ៖ ចឹងពេលដែលពូចូលបដិវត្តហ្នឹង ពូធ្វើអីខ្លះទៅ ពេលចូលទៅដំបូង?

យ៉ុន ៖ អឺ! គ្មានអីទេ ពីដើមខ្ញុំនៅនិរសាគេទេ ។

ធានី ៖ និរសា?

យ៉ុន ៖ បាទ!

ធានី ៖ និសារខាងណាវិញ?

យ៉ុន ៖ និរសា ពីដើមខ្ញុំនៅនិរសាតំបន់ៗ៣៣ៗ ។

ធានី ៖ ៣៣ ព្រែកប្បាស?

យ៉ុន ៖ ព្រែកប្បាស ។

ធានី ៖ ចឹងនិរសាតំបន់ ចុះប្រធានតំបន់ឈ្មោះអី?

យ៉ុន ៖ ខ្ញុំនៅតំបន់បាទម៉ាខែ បានដកយកមកនៅនិរសាឃុំវិញ ។ បន្ទាប់ពីនិរសាឃុំទៅ បានពូៗណាគ នេះគាត់មកយកខ្ញុំទៅ ។ ដល់យកទៅគាត់ក៏ខ្ញុំនៅជាមួយគាត់ផ្ទាល់នេះឯង នៅៗទៅក៏គាត់ តាម៉ៅនេះៗគាត់ទៅសុំពីពូណាគមកវិញ ។ ពូម៉ៅនោះពីដើមមិញគាត់ប្រធានខាងយើង និយាយថាខាងភស្តុភារណ៍ ខាងហ្គារាសឡាន នៅក្នុងឃុំចំប៉ានេះឯង ។

ធានី ៖ ចឹងគាត់ខាងហ្គារាសឡានដែរ?

យ៉ុន ៖ បាទ!

ធានី ៖ ចឹងពូម៉ៅមកយកពូមកធ្វើនៅខាងហ្នឹងធ្វើអីគេ?

យ៉ុន ៖ មកនៅរៀនឡានដែរ ។

ធានី ៖ រៀនឡាន?

យ៉ុន ៖ បាទ!

ធានី ៖ រៀនជួសជុលឡានដែរពូនោះ?

យ៉ុន ៖ បាទ! ព្រោះនៅសន្តិភាពភ្នំពេញទៅក៏ចូលទៅទាំងអស់គ្នា ។

ធានី ៖ ចឹងតែពូអត់បានធ្វើទ័ពទេ?

យ៉ុន ៖ ទេ! ធ្វើតើខ្ញុំ ។

ធានី ៖ ក្រែងពូធ្វើជាអ្នកជួសជុលឡាន?

យ៉ុន ៖ ធ្វើ ទេ! មុនជួសជុលឡាននេះ ខ្ញុំធ្វើៗទ័ព ។ បានតាម៉ៅនេះមកសុំពីនោះមក ។

ធានី ៖ អូ! យល់ហើយ ។ ចឹងពេលដែលសន្តិភាពហើយបានពូម៉ៅគាត់សុំពីពូណាគ តាណាគរបស់ពូហ្នឹង យកមកជួសជុលឡាននៅឆ្នាំ១៩៧៥?

យ៉ុន ៖ បាទៗ ។

ធានី ៖ ចឹងអឺ! ពេលពូនៅជាមួយពូណាគហ្នឹងធ្វើជានិរសារបស់គាត់?

យ៉ុន ៖ បាទ!

ធានី ៖ និរសាហ្នឹងធ្វើអីខ្លះទៅ កាលហ្នឹង?

យ៉ុន ៖ សម្រាប់រត់សំបុត្រ រត់ការណ៍តាមខ្សែត្រៀម ទៅណាក៏ទៅតាមគាត់ ។

ធានី ៖ អូ! ចឹងគាត់ទៅណា ពូទៅដល់ហ្នឹងដែរ?

យ៉ុន ៖ បាទ!

ធានី ៖ តាមខ្សែត្រៀម រត់ហ្នឹងយ៉ាងម៉េចខ្លះទៅពូ?

យ៉ុន ៖ ខុទាហរណ៍ថានាំសារហៅមេៗមកប្រជុំ មានកិច្ចការផ្សារអីត្រូវដកខ្សែត្រៀមដកអីហ្នឹង ទៅរត់តាមនេះ កាត់កាំភ្លើងៗ

ធានី ៖ ចឹងពូរត់?

យ៉ុន ៖ បាទ! ចឹងៗ

ធានី ៖ ចឹងកាលពេលពូនៅធ្វើនិរសារបស់តាណាគហ្នឹង? ចឹងពូនៅធ្វើយាន្តដ្ឋានឡានហ្នឹង នៅរហូតដល់ ខែប៉ុន្មាន ពូថាខែប៉ុន្មាន ពូថាឆ្នាំប៉ុន្មាន ពាក់កណ្ដាល៧៨ បានពូទៅរៀនបន្ថែមទៀតនៅចិន?

យ៉ុន ៖ បាទ!

ធានី ៖ ជាមួយបច្ចេកទេសចិន?

យ៉ុន ៖ បាទ!

ធានី ៖ ចឹងពូនៅរៀនឡានហ្នឹង ពូរៀនតែឡានធ្វើតែឡានម៉ាមុខទេ

យ៉ុន ៖ បាទ!

ធានី ៖ អត់មានធ្វើអីផ្សេងទៀតទេ?

យ៉ុន ៖ អត់ទេៗ

ធានី ៖ ចុះអ្នកណាប្រធាននៅហ្នឹង ពូម៉ៅហ្នឹង?

យ៉ុន ៖ ប្រធានហ្គារាសឡានហ្នឹង មានច្រើន ដំបូងតាម៉ៅ ដល់តាម៉ៅហ្នឹងមិនដឹងជាប់និន្នាការអី ដកតាម៉ៅហ្នឹង មកខាងជីខរ កោះកុបៗ

ធានី ៖ អូ! ពូម៉ៅហ្នឹងចេញពីហ្នឹងហើយ?

យ៉ុន ៖ បាទ! ចេញពីៗហ្គារាសយាន្តដ្ឋាន យើងរួចហើយបានយកលីនឈ្មោះលីនៗ គាត់ជនជាតិភាគតិច យកលីនមកដាក់ៗ

ធានី ៖ ឈ្មោះនីន?

យ៉ុន ៖ បាទ! យកលីនមកដាក់រួចហើយ បានសភាពការណ៍ចាប់មនុស្សវៃចោលក្នុងទីក្រុងភ្នំពេញចាប់អ៊ីៗដូចជានែក! ចេង អនៗ

ធានី ៖ អូ! ចាប់អ៊ីចេង អនទៀត?

យ៉ុន ៖ បាទ! និយាយរួមអ្នកដឹកនាំនយោបាយណា៎ៗ

ធានី ៖ កាលហ្នឹងចាប់អ្នកណាគេខ្លះ?

យ៉ុន ៖ នៅរួចហើយ ។

ធានី ៖ ចេង អន?

យ៉ុន ៖ ច្រើនណាស់... ខ្ញុំក៏ភ័យខ្លួនឯងដែរ និយាយរួមទៅ ។

ធានី ៖ កាលហ្នឹងចុះពូរបស់ពូៗណាគ?

យ៉ុន ៖ ពូខ្ញុំស្លាប់តាំងពីមិនទាន់សន្តិភាព គេយកវៃចោលអស់ ។

ធានី ៖ ពូណាគមេទ័ពហ្នឹង?

យ៉ុន ៖ បាទ! មិនដឹងជាគាត់នៅណា ។

ធានី ៖ ហ៎! ចឹងពូណាគហ្នឹង ពេលសន្តិភាពបានគាត់យកខ្ញុំពីពូណាគមក?

យ៉ុន ៖ បាទ! មុនសន្តិភាពបានគាត់យកៗខ្ញុំពីពូណាគមក ។

ធានី ៖ យក?

យ៉ុន ៖ បាទ!

ធានី ៖ តែពូណាគ គាត់ត្រូវស្លាប់ដោយសារសង្គ្រាម ឬក៏?

យ៉ុន ៖ មិនដឹងជាមូលហេតុអី ។

ធានី ៖ តែក្រោយពីការចាប់ចេង អន ហើយអីៗផ្សេងទៀត បានជំនួសដោយសាអ្នកណាគេ?

យ៉ុន ៖ នែក! ប្រធានខស្សហ៍កម្មនឹង ដកពីខាងទ័ពយកមកដាក់ ។

ធានី ៖ ឈ្មោះអីគេ?

យ៉ុន ៖ អឺ! ស៊ុនៗនឹងមកនៅបាន៣-៤ថ្ងៃ យកទៅទៀតទៅ មិនដឹងជារឿងអីខ្លះ គេតៗគ្នាហ្នឹងឯង ៣-៤ថ្ងៃ ឃើញយកមកដាក់មួយទៀត ៣-៤-៥ថ្ងៃឃើញយកទៅបាត់ទៀត ។ សូម្បីតែខ្ញុំ ថ្ងៃអាទិត្យ ខ្ញុំមិនបានធ្វើការផង ខ្ញុំនៅជាប់ទឹព គេមកចាប់មកសួរ ចុះពួកប៉ុន្មាននាក់ហ្នឹង មិត្ត ប៉ុន្មាននាក់នឹងនៅឯណា? ខ្ញុំថាខ្ញុំមិនមែនខ្ញុំនៅកន្លែងនេះទេ ខ្ញុំនៅយាន្តដ្ឋានខ្ញុំ ប៉ុនខ្ញុំស្នាក់នៅ រៀនបច្ចេកទេសឡាន សាលាទួលគោកចេះណា ។ បានអគ្គការគាត់ថា អឺ!បើមិនចឹងមិនអីទេ ស្នាក់នៅចុះ ។ កុំអីខ្ញុំគេយកទៅជាមួយគេដែរ ដឹងគេយកទៅណា ។

ធានី ៖ ហើយពូស្គាល់ឈ្មោះអ្នកសួរហ្នឹងទេ?

យ៉ុន ៖ កាលនឹងគេហៅមន្ទីរ៨៧០ កាលសម្ភាន់តាឌុច មិនដឹងនៅណា ប៉ុនគានឡង់រ៉ូវើរគេដាក់ចឹងឯង ឡានខ្ចបគេដាក់អាហ្នឹងមក ។

ធានី ៖ អូ! គេដាក់ឡានហ្នឹងមើលមន្ទីរ៨៧០ទៀត?

យ៉ុន : បាទ! ហ្នឹង ជញ្ជូនគ្មានសល់ទេ ។

ធានី : ចុះពូដឹងថាអ្នកណាគេធ្វើការនៅមន្ទីរ៨៧០ហ្នឹង?

យ៉ុន : មិនដែលហ៊ានចូលទេ សូម្បីតែសម្បត្តិ អ៊ំខៀវ សំផន ក៏ខ្ញុំជួបព្រឹកល្ងាច ខ្ញុំមកពីរៀនសាលាទួលគោក ខ្ញុំជិះកង់ឃើញគាត់ពាក់អាវខ្មៅ ។

ធានី : នៅមន្ទីរ៨៧០ហ្នឹង?

យ៉ុន : ទេ! អ៊ំខៀវ គាត់ដើរ តែល្ងាចឡើងគាត់ដើរៗឡាននេះគាត់អត់ជិះទេ និរសាបរតាមក្រោមប្រៀបដូចថាមនុស្សយើងវាអស់សង្ឃឹមដែរណ៎ា តាមខ្ញុំមើលគាត់ ។

ធានី : អ៊ំខៀវ សំផនហ្នឹង?

យ៉ុន : បាទៗ ។

ធានី : ពេលហ្នឹងពូនៅផ្សារថ្មី ហើយម៉េចបានទៅឃើញអ៊ំខៀវ សំផន?

យ៉ុន : ចុះគាត់ តែល្ងាចគាត់ដើរតាមផ្លូវដែរមុខវ៉ារទេះភ្លើង ពីផ្លូវបំបែកទួលគោកមក ឡាន ចុះនិរសាចោល អត់ជិះ ។

ធានី : ចុះពូស្នាក់នៅកន្លែងផ្សារថ្មីនឹង កន្លែងណាវិញ?

យ៉ុន : កន្លែងក្រសួងឧស្សាហកម្ម កន្លែងចេង អនហ្នឹងម៉ង ។

ធានី : ចេង អនហ្នឹងម៉ង?

យ៉ុន : បាទ! ខ្ញុំក៏មិនដឹងថាគេចាប់ចេង អន ពីស្មានណា ស្រាប់តែដល់ព្រឹកឡើងឃើញ ។

ធានី : គេមកចាប់គាត់ ពូឃើញដែរ?

យ៉ុន : ទេ! អត់ទេ ។

ធានី : គ្រាន់ព្ដតែគេនិយាយ?

យ៉ុន : បាទ! បាត់គាត់ទៅឃើញយកអ្នកផ្សេងមកដាក់ ។

ធានី : ចឹងពូស្គាល់តាចេង អនច្បាស់ដែរ?

យ៉ុន : ស្គាល់ អ៊ំវន វេត ក៏ខ្ញុំស្គាល់ ហ៊ូ នឹម ក៏ខ្ញុំស្គាល់ ប៉ុនបាត់រូបទាំងអស់ ។

ធានី : អត់ដឹងថាហេតុអី?

យ៉ុន : មិនដឹងជាមូលហេតុអីទេ ។

ធានី : បានស្គាល់ពីដំបូងដែរ?

យ៉ុន : ច្រើនដែរខ្ញុំ តាំងពីតាម៉ុក តាំងពីណាណៃនោះ ខ្ញុំធ្លាប់ ។

ធានី : ធ្លាប់និយាយជាមួយគាត់ទេ?

យ៉ុន ៖ បាទ! ធ្លាប់ៗ គាត់ក៏ធ្លាប់មកជាស់តឿនរំលឹកខ្ញុំរៀនឡានរៀនអី កាលខ្ញុំនៅក្មេងៗមក ។

ធានី ៖ កាលហ្នឹងអ្នកណាគេខ្លះ ដូចថាអ៊ំខៀវ សំផន ពូបានឃើញគាត់ដើរតាមផ្លូវ?

យ៉ុន ៖ បាទ! នោះហើយ ។

ធានី ៖ ហើយដល់ពេលតាម៉ុក គាត់ជាស់តឿន?

យ៉ុន ៖ តាៗ ខ្ញុំស្គាល់កាលសម័យសង្គ្រាម ចាញ់យួនណា ហើយយួនចេញមកនាំគ្នារត់ចោលសម្បត្តិ ឲ្យមកនៅតស៊ូ ។

ធានី ៖ នៅតស៊ូនៅខាងក្នុងព្រៃហ្នឹង?

យ៉ុន ៖ បាទ! ខាងព្រំដែនៗ ។

ធានី ៖ ចុះអ្នកណាដែលពូស្គាល់នៅក្នុងសម័យខ្មែរក្រហម មានតែតាអ៊ំខៀវ សំផនមួយទេ?

យ៉ុន ៖ អ៊ំអៀង សារី ក៏ខ្ញុំស្គាល់សព្វថ្ងៃគាត់នៅនោះ ពីដើមកាលពីសម័យយួនខ្ញុំទៅរៀននយោបាយ អ៊ំអៀង សារី រៀនតាមព្រំដែន ។

ធានី ៖ កាលពីឆ្នាំ៧៩នេះ?

យ៉ុន ៖ ចាប់ពី៧៩ មកទល់យើងសន្តិភាព បានខ្ញុំឈប់មុនអ៊ុនគាត់ ។

ធានី ៖ ចឹងបន្តមកទៀត ពេលដែលពូនៅឆ្នាំ៧៨ ពូរៀននឹងហើយ ពូទៅណាទៀតទៅ?

យ៉ុន ៖ ៧៨ ។

ធានី ៖ រៀនជាមួយចិននោះ ដែលថាគេមកបង្រៀនបច្ចេកទេសឡានថែមនោះ?

យ៉ុន ៖ រៀនៗរួចៗ ខ្ញុំគេដកទៅវ៉ៃបារីក ។

ធានី ៖ គេឲ្យពូ ពេលនឹងពូមានងារជាអី?

យ៉ុន ៖ អត់ទេ មិនមានអីទេ ។

ធានី ៖ ជាទ័ពធម្មតា?

យ៉ុន ៖ បាទ! ដល់នេះក៏ជិតចូលយួនទៅក៏ខ្ញុំបរឡានដឹកទ័ពឆ្លងត្រើយកើតមក ។

ធានី ៖ ត្រើយបារីតហ្នឹងមកវិញ?

យ៉ុន ៖ បាទ! ចាប់ពីយើងរោងចក្រជីឥដ្ឋ ក្តារបន្ទះ រហូតមកដល់យើងភ្នំពេញក៏គេរត់អស់ ។

ធានី ៖ ចឹងពូអញ្ជើញទៅណាវិញទៅ?

យ៉ុន ៖ ចុះមនុស្សខ្ញុំទាន់កន្ទុយអូរនៅចុងពោធិ៍ចិនតុង ទាន់ត្រឹមនោះ ។

ធានី ៖ ហើយពូទៅដល់ណាខ្លះទៅពូ?

យ៉ុន ៖ អូ! ច្រើនណាស់ វ៉ៃតាមផ្លូវរបូត របូតតាមពីនឹងមករហូតមកដល់ផ្លូវយើងកោះក្រឡ មកផ្លូវ យើងហៅស្ទឹ ភ្នំសំពៅ ភ្នំអី ។

ធានី ៖ អូ! ទៅភ្នំសំពៅយើងបាត់ដំបង?

យ៉ុន ៖ បាទ! នោះ មកតាមនឹងរហូត ។

ធានី ៖ រហូតដល់ណា?

យ៉ុន ៖ បាទ! ធ្លាក់មកព្រៃធំយើងនេះ ។

ធានី ៖ ព្រៃធំហ្នឹងនៅណា?

យ៉ុន ៖ ព្រៃធំ ធ្លាក់មកបវេល ៗ ធ្លាក់មកលើកយើងសាយសាម៉ន ។

ធានី ៖ សាយសាម៉ន ហើយដល់ណាទៀត?

យ៉ុន ៖ សាយសាម៉ន អាហ្នឹងចាញ់មែនទែនហើយ ដល់អូរស្រឡៅធ្លាក់ចូលដីថៃហើយ ។

ធានី ៖ ចឹងពូទៅដល់អូរស្រឡៅដែរ?

យ៉ុន ៖ ទៅអូរស្រឡៅ ។

ធានី ៖ នៅម៉ាឡៃ?

យ៉ុន ៖ បាទ! ម៉ាឡៃ ទៅអូរស្រឡៅ អូរសំព័រ ខ្វាងរាប ។

ធានី ៖ ខ្វាងរាបអី ចឹងពូវ៉ៃតាមដំនៀរតាមនឹងរហូត?

យ៉ុន ៖ វ៉ៃ ។

ធានី ៖ ពេលណាទៅពូ ដែលមកដល់អូរស្រឡៅ ខ្វាងរាបអីហ្នឹង ឆ្នាំប៉ុន្មានពូដឹង?

យ៉ុន ៖ នេះដំបូង៧៩ មិនដឹងថ្ងៃទីប៉ុន្មាន ខ្ញុំភ្លេចហើយអត់បានចាំ ។

ធានី ៖ ពេលដែលពូចូលទៅដល់ទឹកដីម៉ាឡៃនឹងដំបូង ភូមិនេះ ពេលណាវិញ មកសាយសាម៉នហ្នឹង ពេលណា ព្រោះសាយសាម៉នៅទឹកដីបាត់ដំបង?

យ៉ុន ៖ បាទ! បាត់ដំបង ។

ធានី ៖ គៀក ៗ ?

យ៉ុន ៖ វាមិនបានចាំថ្ងៃ ។

ធានី ៖ ប៉ុន្តែក្នុងឆ្នាំ៧៩ដដែល?

យ៉ុន ៖ បាទ! ៧៩ ។

ធានី ៖ ពេលពូមកដល់ម៉ាឡៃដំបូងឃើញម៉េចដែរ?

យ៉ុន ៖ អឺ! លំបាកណាស់ ចាស់ៗពីដើមមានពាក្យស្លោកថាចុះទឹកក្រពើឡើងលើខ្លា ពេលនឹងយើងវ៉ៃ ថៃផង យើងចាញ់យួនផង បើកាលនោះខាងផ្នែកគណៈទាក់ទងខាងខាងនយោបាយ ក៏យើង អត់ទាក់ទងបានផង ដល់ចឹងដើរតាមបាតប្រឡាយបាតអូរ វាអត់ឡើងឲ្យចូលដីថៃ ។

ធានី ៖ ម៉េចចឹងពូ?

យ៉ុន ៖ ព្រោះយើងអត់ទាក់ទងបានវា ហើយយើងវ៉ៃជាមួយវាផង កាលនោះ ។

ធានី ៖ វ៉ៃជាមួយថៃទៀត?

យ៉ុន ៖ ចុះមុន៧៩ វ៉ៃថៃមើលឆ្អឹងមិនទាន់បាត់អស់ រថក្រោះអីឆេះទៀត ចឹងបានថាដល់ចឹងទៅ គណៈទាក់ទងព្រំដែន ក៏គេឲ្យទៅចូលជ្រៅ បានដើរអែបថ្នល់ជាតិគេ ។ អានេះនិយាយរួមទៅ មហិចតាវាធំដែរ ដល់ចឹងផ្ទុះសំយ៉ាប់ជាប់គ្នា ដល់ចឹងគេសុខចិត្តយកយើងធ្វើរបង សត្រូវ ក្លាយជាមិត្តដើម្បីអី ការពារផលប្រយោជន៍របស់គេ ។

ធានី ៖ ត្រូវហើយ បើមិនចឹងទេអស់?

យ៉ុន ៖ បាទ! កុំអីអស់ ។

ធានី ៖ កុំអីវ៉ៃខ្ទេចខ្ទី ។

យ៉ុន ៖ បាទ! ម៉ត់ហើយ ។

ធានី ៖ ចឹងពូចង់សុំឲ្យពូជួយរៀបរាប់កន្លែងពេលដែលពូចូលទៅដល់សាយសាម៉ន ទៅដល់ម៉ាឡៃនឹង វាដូចជាស្រុកភូមិយើងដែរ ឬក៏វាខុសគ្នាពីស្រុកភូមិយើងវាយ៉ាងម៉េចពូ?

យ៉ុន ៖ វាដល់នៅក្នុងកាលនោះមិនទាន់មានស្របជាជនទេ មានតែទ័ពសុទសាធ ។

ធានី ៖ ហើយម៉េចបានពូទៅដល់ហ្នឹង ដូចថាមានអ្នកណាគេអ្នកផ្តើមគំនិតដំបូងដែលយើងរត់ ត្រូវរត់ ទៅដល់នឹង?

យ៉ុន ៖ ពីព្រោះអី គណៈទាក់ទងយើង គាត់ទៅមុន អ្នកដឹកនាំធំៗ ដូចថាអ៊ំខៀវអី គាត់ចេញមុនម៉ា ថ្ងៃ ២ថ្ងៃ គាត់ទៅមុនទៅក្រោយ ដល់ចឹង យើងចាញ់យួនហើយ យើងមានទៅណា មាន តែជ្រកគេ ប៉ុនថា ។

ធានី ៖ អ៊ំខៀវ គាត់ប្រាប់ថាឲ្យទៅនៅខាងនឹងឬយ៉ាងម៉េច?

យ៉ុន ៖ បាទ!

ធានី ៖ បានយើងនាំគ្នារត់ទៅខាងទល់ដែន?

យ៉ុន ៖ បាទ! មានចលអី ចលនាតស៊ូព្រៃលាក់ខ្លួនមានណាមានតែនឹងឯង មើលតាម៉ុកគាត់អ្នកដឹកនាំទៅរបូត ។

ធានី ៖ តាម៉ុកគាត់អ្នកដឹកនាំទៅ ពីភ្នំពេញទៅ?

យ៉ុន ៖ បាទៗ របូត ចឹងគាត់អ្នកដើរព្រៃដែរ ។

ធានី ៖ ចឹងគាត់អ្នកដើរព្រៃដែរ?

យ៉ុន ៖ ចុះគាត់អ្នកកសិករសុទ្ធសាធ គាត់បញ្ញវ័ន្តមែន ប៉ុនគាត់កសិករ ។

ធានី ៖ ចឹងអ្នកដើរព្រៃនឹង យើងទៅរុកព្រៃខ្លួនឯងឬមួយក៏យ៉ាងម៉េច ឬមួយក៏មានអ្នកគេ?

យ៉ុន ៖ មានធ្លាប់មាន ។

ធានី ៖ ព្រោះព្រៃហ្នឹងវាធំអីចឹង?

យ៉ុន ៖ ធំណាស់ ទាល់តែមានមេខ្យល់ មានអ្នកដឹកនាំទៅ ស្គាល់ភូមិសាស្រ្ត ។

ធានី ៖ ពូស្គាល់ឈ្មោះគាត់ទេ អ្នកដឹកនាំទៅ?

យ៉ុន ៖ ទេ! ខ្ញុំមិនស្គាល់ទេ ព្រោះទ័ពរាប់ម៉ឺន ។

ធានី ៖ មនុស្សច្រើន ពេញវន្ដីលព្រៃ?

យ៉ុន ៖ បាទ! រាប់ម៉ឺនរាប់ពាន់នាក់ ។

ធានី ៖ ចឹងពូកាលហ្នឹង ពូថាពូធ្វើប្រធានវរៈៗនឹងពេលនៅនឹង ឬមួយក៏?

យ៉ុន ៖ ទេ! ខ្ញុំអត់ទេ ទាល់តែខ្ញុំឆ្លងមកពីខាងត្បូងថ្មល់វិញ មកវ៉ៃខាងនេះបាន២ឆ្នាំបានបេះឡើងមក តិចៗទៅណា ។

ធានី ៖ ចឹងកាលពេលមកនៅម៉ាឡៃនឹងអត់ទាន់ទេ?

យ៉ុន ៖ គ្មានអីទេ ។

ធានី ៖ ជាទាហានធម្មតា?

យ៉ុន ៖ បាទ! ធម្មតា ។

ធានី ៖ ចឹងចង់សួរពូថា ដល់ពេលពូមកដល់ម៉ាឡៃឃើញព្រៃក្រាស់ព្រៃ យប់ឡើងវាមានស្អីខុសប្លែកពីយើងដែរអត់ទេ?

យ៉ុន ៖ អូ! តំបន់គ្រុនចាញ់ មានអង្រឹង អត់មានអីទេ ។

ធានី ៖ គ្រុនចាញ់ៗច្រើនទេ?

យ៉ុន ៖ យប់ឡើងភ្លឺដូចភ្លឺពិលយើងចឹង ដីជាតិបារតតំបន់ចាញ់ ដីម៉ាឡៃ ។

ធានី ៖ ចឹងអ្នកដែលទៅនឹងគ្រោះថ្នាក់ច្រើន?

យ៉ុន ៖ អត់អីទេ ដូចថាទេពតាជួយដែរ ថ្នាំពេទ្យក៏អត់ទាន់មានមន្ទីរពេទ្យក៏យើងអត់ទាន់ពង្រឹងបាន កំពុងតែបែកបាក់ យើងកំពុងការពារកម្លាំង ។

ធានី ៖ ប៉ុន្តែទាហានអស់នឹងគាត់មាំទាំងអស់?

យ៉ុន ៖ បាទ! បាយក៏មិនមានហូបដែរ ហូបតែត្រកួន ត្រពាំង មានប៉ុននោះឯង ទាល់តែបានម៉ា អាទិត្យបានមានអង្ករមក ៗ មានតែ៤-១០ឡានម៉េចគ្រប់ ម៉ាក្រុមបានតែ៥កំពុង បបរហូប លាយដំឡូងខ្យាងអីទៅ ។

ធានី ៖ ពិបាកពូនោះ?

យ៉ុន ៖ អូ! ការតស៊ូមិនងាយទេ ។

ធានី ៖ ដល់ពេលក្រោយមកម៉េចទៀត ពូនោះដល់ពេលបានអង្ករបានអី ចុះមានវៃជាមួយយួនទៀត ទេ?

យ៉ុន ៖ អត់ទេ ស្ថិតក្នុងលក្ខណៈការពារខ្លួន យើងពង្រឹងខ្លួនឯង ដល់យើងហូបមានបាយហូបគ្រប់ គ្រាន់បានមានចលនាតស៊ូ ។

ធានី ៖ ចុះពូដឹងថាអ្នកណាគេអ្នកចង់ក្រងនៅម៉ាឡៃនឹង ចាប់ផ្ដើមជាក្រុមជាទ័ពជាទាហានកង?

យ៉ុន ៖ គិត ៗ ទៅវាមេ ៗ តា ៗ នឹងបន្ត ៗ គ្នាទាំងអស់គ្នា បើយើងនិយាយមែនទែន ។

ធានី ៖ អ្នកណាគេអ្នកផ្ដើមដំបូង ហើយបន្ទាប់មកទៀតអ្នកណាគេ?

យ៉ុន ៖ បាទ! មានតែពួកតា ៗ អ៊ំខៀវ សំផន អ៊ំអីហ្នឹង ។

ធានី ៖ អ៊ំខៀវ សំផន?

យ៉ុន ៖ បាទ! ពួកតាម៉ុកតាអី ។

ធានី ៖ តាម៉ុក ពុថា អ៊ំអៀង សារីដែរ?

យ៉ុន ៖ បាទ! គ្នាគាត់ហ្នឹង ។

ធានី ៖ ដែលថាប្រជុំជាមួយគ្នាហ្នឹង គឺប្រជុំនៅម៉ាឡៃហ្នឹង?

យ៉ុន ៖ បាទ! អាហ្នឹងដល់ខែទៅរៀន គេហៅមេ ៗ ទៅរៀន ។

ធានី ៖ ហៅពូទៅរៀនដែរ?

យ៉ុន ៖ បាទ!

ធានី ៖ រៀនហ្នឹងរៀនម៉េចខ្លះទៅពូ?

យ៉ុន ៖ រៀន ៗ មានរៀនអី រៀននយោបាយ ក្បួនវៃក្បួនអី ។

ធានី ៖ អ្នកណាគេខ្លះមកបង្រៀន ពូអ៊ំ ៗ ណាខ្លះមកបង្រៀន?

យ៉ុន ៖ មានអ៊ំអៀង សារី កងពលក៏មានបងសារឿន តាហុង ។

ធានី ៖ តាហុងហើយអ្នកណាគេទៀត ចុះអ៊ី!សុខ ភាពនោះ?

យ៉ុន ៖ សុខ ភាព!

ធានី ៖ ចាំ! តាភាព ។

យ៉ុន ៖ ខ្ញុំកងពលផ្សេង ខ្ញុំ៥១៩ ។

ធានី ៖ នៅជាមួយតាកនតាអ៊ីហ្នឹង?

យ៉ុន ៖ ទេ! ខ្ញុំបងសារឿនខាងនេះបណ្តោយ ។

ធានី ៖ ខាងនេះវិញ?

យ៉ុន ៖ បាទ!

ធានី ៖ ប៉ុន្តែម៉េចបានពូទៅរៀននៅម៉ាឡៃ?

យ៉ុន ៖ ចុះកន្លែងអគ្គបញ្ជាការធំហ្នឹងហើយ ។

ធានី ៖ អូ! ចឹងអគ្គបញ្ជាការធំគឺនៅម៉ាឡៃ?

យ៉ុន ៖ បាទ!

ធានី ៖ ហើយម៉ាឡៃជាកន្លែងប្រមូលផ្តុំ ខាងកងពលផ្សេងៗមករៀននៅហ្នឹង?

យ៉ុន ៖ កន្លែងជារួមទៅ កន្លែងមូលដ្ឋានរបស់ទ័ពតែម៉ង ទាំងគ្រួសារទ័ពអីគេយកដាក់ហ្នឹងទាំងអស់ ។

ធានី ៖ ចឹងខាងទ័ពអ៊ី ឈាន អីដែលគាត់នៅប៉ៃលិន ក៏មករៀន?

យ៉ុន ៖ ទេ! ខាងទ័ពប៉ៃលិនគាត់រៀននៅខាង១០២នោះ ។

ធានី ៖ ១០២ក្រែងម៉ាឡៃ ។

យ៉ុន ៖ ១០២នៅខាងនោះទៀត ជិតចូលដល់ប៉ៃលិន ។

ធានី ៖ ជិតចូលដល់ប៉ៃលិន?

យ៉ុន ៖ បាទ! រៀននោះទៅរៀនថ្នាក់ដូចពួកឈានអីចេះ ទាល់តែថ្នាក់កងពលបានៗទៅរៀន ត្រឹមវរសេនាធំអីរៀនត្រឹម ។

ធានី ៖ ត្រឹមម៉ាឡៃទេ?

យ៉ុន ៖ ត្រឹមម៉ាឡៃ ។

ធានី ៖ ចឹងកាលពេលមករៀន អ្នកណាខ្លះមកបង្រៀនពូ?

យ៉ុន ៖ មានតែអ៊ំអៀង សារីប៉ុននោះ ។

ធានី ៖ កាលហ្នឹងពូធ្វើវរសេនាធំហើយ ។

យ៉ុន ៖ បាទ!

ធានី ៖ ប្រធានវរសេនាធំ?

យ៉ុន ៖ បាទ!

ធានី ៖ ឆ្នាំប៉ុន្មានហើយកាលនឹង?

យ៉ុន ៖ ខ្ញុំធ្វើបានប៉ុន្មាន ៣-៤ឆ្នាំ ។

ធានី ៖ កាលហ្នឹងឆ្នាំប៉ុន្មាន ៩០ជាង ឬ៨០ជាង?

យ៉ុន ៖ ៩០ ប្រហែលជាចូល ក្បែរ៩០ហើយ ។

ធានី ៖ អាចថា៨៩ ៩០?

យ៉ុន ៖ បាទ!

ធានី ៖ ចឹងចុះពេលពូទៅ មិនពូថារត់ទៅ៧៩ ឆ្នាំ១៩៧៩រត់ទៅម៉ាឡៃ ហើយពេលណាបានពូត្រឡប់ មក នៅនឹងប៉ុន្មានឆ្នាំបានមកដល់នេះ?

យ៉ុន ៖ ១៩៨០បានឆ្លងមក ។

ធានី ៖ ១៩៨០បានរត់ចូលមកស្រុកយើង?

យ៉ុន ៖ ឆ្លង បានខាងលើចែកកងទ័ព ។

ធានី ៖ ចែក ឲ្យពូទៅខាងណា?

យ៉ុន ៖ មកស៊ីសាផុនដើង ។

ធានី ៖ មកស៊ីសាផុន ។ ហើយខាងណាអ្នកដឹកនាំមក?

យ៉ុន ៖ ជួរខាងក្រោមៗខាងលើហ្នឹង ។

ធានី ៖ ដូចថាឈ្មោះអី គាត់អ្នកដឹកនាំមក?

យ៉ុន ៖ ដែលនាំមក?

ធានី ៖ ចាំ!

យ៉ុន ៖ បងសារឿន ។

ធានី ៖ បងសារឿន?

យ៉ុន ៖ បាទ!

ធានី ៖ ស្អីគេសារឿន?

យ៉ុន ៖ មិនបានចាំនាមត្រកូលគាត់ទេ ។

ធានី ៖ ហើយចុះរាល់ថ្ងៃគាត់ធ្វើការទ័ពដែរ?

យ៉ុន ៖ គាត់ឈប់ហើយ ។

ធានី ៖ ឈប់ដែរ ។ អូ!ចឹងសារឿនហ្នឹងគាត់អ្នកដឹកនាំទ័ពប៉ុន្មានទ័ព បានមកដល់នេះ?

យ៉ុន ៖ កងពល ។

ធានី ៖ ម៉ាកងពល?

យ៉ុន ៖ បាទ!

ធានី ៖ ម៉ាកងពលមកដល់នេះ ហើយពូមកធ្វើនៅនេះ នៅឆ្នាំ៩០ បានពូឡើងធ្វើប្រធានវរៈសេនាធំ វរៈសេនាតូច?

យ៉ុន ៖ វរសេនា ។

ធានី ៖ ប្រធានវរសេនាធំ វរសេនាតូច?

យ៉ុន ៖ ប្រធានវរសេនាធំនែក! ឈ្មោះ ធាន ។

ធានី ៖ ចឹងពូប្រធានវរសេនាតូច?

យ៉ុន ៖ ទេ! ខ្ញុំរងគាត់ ។

ធានី ៖ ចឹងពូអនុប្រធានវរសេនាធំ?

យ៉ុន ៖ បាទ! រងគាត់ ។

ធានី ៖ វរសេនាធំ អនុប្រធានទេ ហើយប្រធានឈ្មោះអីគេ មិញពូសុំម្តងទៀត?

យ៉ុន ៖ យី! ភ្លេចនាមត្រកូលគាត់ ខ្ញុំចាំតែធាន ។

ធានី ៖ ឈ្មោះអី ធាន?

យ៉ុន ៖ ស្អីធាន ។

ធានី ៖ ហើយចឹងចុះពូថាពូនៅនឹងបាន២-៣ឆ្នាំ ហើយម៉េចបានគេដកពូដូចគុម្ពស្ដែម៉េចនោះ?

យ៉ុន ៖ នោះ ។

ធានី ៖ រឿងហេតុអីគេពូ សុំពូប្រាប់ពីមូលហេតុដំបូង?

យ៉ុន ៖ នាំពិបាកមានរឿងច្រើនទៀត ។

ធានី ៖ គ្រាន់ដឹងថាមានទំនាស់ផ្ទៃក្នុងនៅក្នុងកងពលហ្នឹង?

យ៉ុន ៖ បាទៗ ។

ធានី ៖ ពេលហ្នឹងពូ តាសារឿនហ្នឹងគាត់នៅក្ដាប់ដែរ?

យ៉ុន ៖ នៅ ប៉ុនគាត់រងគេ ឈ្មោះហុងហ្នឹងបានប្រធានកងពលធំ ។

ធានី ៖ តាហុងនឹងមែន?

យ៉ុន ៖ បាទ!

ធានី ៖ សូ ហុង?

យ៉ុន ៖ បាទ! ហ្នឹងហើយ ប្រធានកងពលធំ បងសារឿងនោះរង ។

ធានី ៖ ចឹងសូ ហុងហ្នឹង ប្រធានកងពល នឹងគេហៅប្រធានកងពលលេខប៉ុន្មាន?

យ៉ុន ៖ ៥១៩ ។

ធានី ៖ កងពល៥១៩?

យ៉ុន ៖ បាទ!

ធានី ៖ ក្រែងសូ ហុងនឹងគេ ។

យ៉ុន ៖ សព្វថ្ងៃនៅសាយសាម៉ន ។

ធានី ៖ ចាំៗ គាត់នៅរស់តើពូ?

យ៉ុន ៖ នៅរស់តើ ។

ធានី ៖ ហ្នឹងហើយ ពេលខ្ញុំទៅម៉ាឡៃ ខ្ញុំក៏ចង់ជួបគាត់ដែរ ។ តែគៀកពេកទៅវិលអត់បានជួបគាត់វិញ ចង់ជួបដែរតើ?

យ៉ុន ៖ បាទ!

ធានី ៖ ចឹងសូ ហុងនឹងគាត់អ្នកគ្រប់គ្រងកងពល៥១៩ ពូនៅក្នុងកងពលហ្នឹង?

យ៉ុន ៖ បាទ!

ធានី ៖ ដល់ពេលមានបញ្ហាទៅ ក៏ពូឈប់ធ្វើនៅឆ្នាំប៉ុន្មាន ឈប់ធ្វើទាហាន?

យ៉ុន ៖ មុនៗគិតទៅមុនអ៊ុនតាក់ចូល ។

ធានី ៖ មុនសមាហរណកម្មទៀត?

យ៉ុន ៖ ប្រហែល៤-៥ខែ ។

ធានី ៖ ចឹងមុនអ៊ុនតាក់ចូល ១៩៩៣ហ្នឹង?

យ៉ុន ៖ ៩៣ ។

ធានី ៖ មុន៤-៥ខែ?

យ៉ុន ៖ បាទ!

ធានី ៖ ចាំ! ហើយចឹងពេលក្រោយទៅបានពូរត់មកនៅនេះវិញ?

យ៉ុន ៖ បាទ!

ធានី ៖ ចុះពេលពូនៅម៉ាឡៃហ្នឹង ពូធ្វើទាហានដែរវ៉ើជាមួយវៀតណាមដែរអត់ទេ អត់ទេរត់មកនៅនេះវិញ?

យ៉ុន ៖ ទេ! វ៉ើ ប៉ុនគេចែកកងទ័ពនៅតាមព្រំដែន កម្លាំងវាច្រើនកកកុញទៅ ។

ធានី ៖ ចឹងពូអាចជួយប្រាប់តិចមើលគេចែកកម្លាំងប៉ុន្មានកម្លាំងខ្លះ ដូចនៅម៉ាឡៃ កងទ័ពអី?

យ៉ុន ៖ ៤៥០ហ្នឹង ។

ធានី ៖ ៤៥០ម៉ាឡៃ អ្នកណាអ្នកគ្រប់គ្រង សុខ ភាព ឬក៏សូ ហុង?

យ៉ុន ៖ ភាពៗ សុខ ភាព ។

ធានី ៖ សុខ ភាពអ្នកគ្រប់គ្រង ហើយដល់ពេល៩១៩បានសូ ហុងវិញ?

យ៉ុន ៖ បាទ!

ធានី ៖ ប៉ះដឹបូងមិនមែនសូ ហុង?

យ៉ុន ៖ មិនមែនទេ បងសារឿន ។

ធានី ៖ ចឹងដំបូងបងសារឿនហ្នឹង ក្រោយទៅបានសូ ហុងនឹងប្រធានវិញ?

យ៉ុន ៖ បាទ! ទេ! ពីដើមមិញវាកងពលតូច មកនេះណា កងពលតូចនោះបងសារឿនអ្នកទទួលខុសត្រូវ ។ ដល់គេបង្កើតកងពលធំទៅ បានយកពូហុង យកមកដាក់ពីលើ ដល់នេះបានបងសារឿន គាត់ឡើងវង ។

ធានី ៖ ចា៎! ដល់ពេលសុខ ភាព គេនៅនោះធំជាង?

យ៉ុន ៖ បាទ! ដល់ចឹង ។

ធានី ៖ ព្រោះកាលមុនសុខ ភាព គាត់អ្នកនៅក្រោមសូ ហុងទេ?

យ៉ុន ៖ បាទ! កាលនោះតាហុងនៅនោះឯង ដឹងបងភាព គាត់ទំនាស់គ្នាយ៉ាងម៉េច បានគេដកយកមកនេះ ។

ធានី ៖ អត់ដឹងដែរ?

យ៉ុន ៖ អឺ!

ធានី ៖ ហើយបន្ទាប់មកទៀត ពូមានដឹងថា នៅខាងតាកនហ្នឹងកងពលលេខប៉ុន្មាន?

យ៉ុន ៖ តាកន មិនមែន៣២០ទេណា៎ ។

ធានី ៖ តាកន?

យ៉ុន ៖ អឺ!

ធានី ៖ តាកន ៣២០ ចុះអ៊ី ឈាននោះ?

យ៉ុន ៖ អ៊ីឈាននោះ មិនដឹងប៉ុន្មានទេ ច្រើនណាស់ ។

ធានី ៖ ១០២ កន្លែងប្រជុំទេ អត់ចាំទេពូ?

យ៉ុន ៖ អត់ចាំៗមិនបានអស់ វាច្រើនឆ្នាំទៅវាសាបរលាប ថាលះបង់អស់ឈប់គិតឈប់គូកំប៉េច កំប៉ុកអស់ហើយ ។

ធានី ៖ ហើយចឹងពេលពូមកដល់ភូមិនេះដំបូងម៉េចទៅ ពេលនឹងមានទំនាស់ ពូថាមានគេចោទថាប៉ាវ៉ា ម៉េចនោះ ពូអាចជួយប្រាប់កន្លែងនឹងតិចទៀត បានទេ ។ គេថាពូប៉ាវ៉ាម៉េចនោះ?

យ៉ុន ៖ ទេ! គេចោទថាខ្ញុំនៅខ្មែរក្រហម នៅក្បត់ជាតិ ខ្ញុំមិនព្រមឈប់ណា ពេលនោះកម្លាំងត្រីភាគី គេរួមច្របាច់ជាមួយរដ្ឋាភិបាលកម្ពុជា ។ ដល់ចឹងវាថា៣៧រៃមួយ បាទ! ហ្នឹងហើយ ត្រូវហើយ ។

ធានី ៖ ដល់ពេលហើយ ពូឈប់ធ្វើ ពូមកនេះ ខាងយើងនេះ?

យ៉ុន ៖ ពូនៅខាងក្រៅ ។

ធានី ៖ ដល់ពេលចឹងខាងយើងនេះ គេថាពូ?

យ៉ុន ៖ ខ្ញុំនៅតែរួមដៃជាមួយគេ ។

ធានី ៖ ខាងណា អ្នកណាគេមកចោទពូចឹង?

យ៉ុន ៖ ទេ! កាលនោះបងនេះ ។

ធានី ៖ ឈ្មោះអីគេ?

យ៉ុន ៖ ដឹងខាងណា ឃឹម សោភ័ណ្ឌដឹងយ៉ាងណាតំបន់៥ មិនដឹងយ៉ាងម៉េច ខ្ញុំមិនសូវចាំ ។

ធានី ៖ អឺ! ចឹងពូសុំសួរតិច ពូមានឈ្មោះអីដែរ ឈ្មោះពេញ?

យ៉ុន ៖ ឈ្មោះ សូ យ៉ុន ។

ធានី ៖ អីគេយ៉ុន?

យ៉ុន ៖ សូ យ៉ុន ។

ធានី ៖ មិនមែនបងប្អូនសូ ហុងទេ?

យ៉ុន ៖ ទេ! មិនមានវាសនាទេ ។

ធានី ៖ ពូឆ្នាំហ្នឹងអាយុប៉ុន្មានហើយ?

យ៉ុន ៖ ៥៣ ។

ធានី ៖ ៥៣ ពូរស់នៅណាដែរ?

យ៉ុន ៖ ភូមិយាងវាន ឃុំផ្កាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឪពុកពូឈ្មោះអីគេ?

យ៉ុន ៖ សូ យ៉ន ។

ធានី ៖ គាត់ស្លាប់ហើយ?

យ៉ុន ៖ ស្លាប់អស់ហើយ ។

ធានី ៖ ដោយរសាអីគេ?

យ៉ុន ៖ ឈឺ ។

ធានី ៖ ឆ្នាំប៉ុន្មានទៅ?

យ៉ុន ៖ អូ! ខ្ញុំនៅព្រៃដែល ខ្ញុំនៅវើទន្លេសាប ។

ធានី ៖ ចាំឆ្នាំទេ កាលហ្នឹងពូ?

យ៉ុន ៖ អត់ចាំ ។

ធានី ៖ ព្រោះពូចូលព្រៃឆ្នាំ៧៣?

យ៉ុន ៖ គាត់ទើបស្លាប់នៅស្រុកគេនេះ ។

ធានី ៖ ស្រុកគេនេះ?

យ៉ុន ៖ បាទ! ស្លាប់នៅភ្នំធំ បឹងព្រីង ។

ធានី ៖ ចាំទាំងអស់ទៀតពូ ភ្នំធំ បឹងព្រីង? ម្ដាយឈ្មោះអីគេ?

យ៉ុន ៖ អឺ! ជីតាគាត់ឈ្មោះអី ឡាំង យ៉ុន ចឹង ។

ធានី ៖ ឡាំង យ៉ុន?

យ៉ុន ៖ បាទ!

ធានី ៖ គាត់ស្លាប់?

យ៉ុន ៖ ស្លាប់ទាំងអស់នៅបឹងព្រីងហ្នឹង ។

ធានី ៖ អូ! ចឹងទាំង២នាក់?

យ៉ុន ៖ បាទ!

ធានី ៖ បងប្អូនពូមានប៉ុន្មាននាក់?

យ៉ុន ៖ បងប្អូនខ្ញុំស្លាប់អស់ហើយ ប៉ុនចំនួនមើលប៉ុន្មានទេ ៨ ប្រុស៤ ស្រី២ ៦ ។

ធានី ៖ ៦នាក់?

យ៉ុន ៖ បាទ!

ធានី ៖ ប្រុស៤ ស្រី២ ៦នាក់?

យ៉ុន ៖ បាទ!

ធានី ៖ ប្រុស៤ ស្រី២ ហើយនៅសល់តែពូម្នាក់ទេ?

យ៉ុន ៖ នៅ២នាក់ ។

ធានី ៖ ស្រី១ ប្រុស?

យ៉ុន ៖ នៅប្រុសទាំង២ ។

ធានី ៖ អ្នកផ្សេងស្លាប់ដោយសារអីដែរ?

យ៉ុន ៖ បងខ្ញុំស្លាប់នឹងទាហាន ។

ធានី ៖ ចឹងស្លាប់ពេលខ្មែរក្រហមទាំងអស់គ្នា?

យ៉ុន ៖ បាទ!

ធានី ៖ ដោយសារទាហាន ដាក់...?

យ៉ុន ៖ បាទ!

ធានី ៖ ចឹងមានបានរៀនបានសូត្រអីទេ ពីមុនមក?

យ៉ុន ៖ រៀនថ្នាក់ទី១១ពីសង្គម គ្មានបានរៀនអីគេ ប្រុងចូលក៏ស្រុកកើតសង្គ្រាម ។

ធានី ៖ ហើយមកដល់រាល់ថ្ងៃពូ ចុះពូរៀបគ្រួសារនៅឆ្នាំប៉ុន្មានដែរ?

យ៉ុន ៖ មិនបានចាំទេ មើលមិនដឹងឆ្នាំប៉ុន្មាន?

ធានី ៖ ៩០ជាង ឬ៨០ជាង?

យ៉ុន ៖ ប៉ុន្មានឆ្នាំ ។

សើយ ៖ ៨៩ ។

យ៉ុន ៖ ៨៩ដឹង ប៉ុននោះឯង ។

ធានី ៖ ១៩៨៩ រៀបគ្រួសារ?

យ៉ុន ៖ បាទ!

ធានី ៖ មានកូនប៉ុន្មាននាក់ពូ?

យ៉ុន ៖ កូននោះ៣នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យ៉ុន ៖ ស្រី២ ប្រុស១ ។

ធានី ៖ ដូចជាអស់អីសួរពូហើយ?

យ៉ុន ៖ បានហើយនោះ ។

ធានី ៖ ចាំ! ចឹងពូអត់មានអីចង់សួរខ្ញុំវិញទេ?

យ៉ុន ៖ ទេ! គ្រប់គ្រាន់ ។

ធានី ៖ ចាំ! អរគុណពូច្រើនហើយ ។

យ៉ុន ៖ បាទ! អរគុណ ។

ធានី ៖ ពូសុំថតរូបតិចពូនោះ ។

«ចប់»